**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** :..........១៩៨១..........**ក.ប** /ខ.ល

## សារលិខិតជូនពរ

### សូមគោរពជូន សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ប្រធានកាកបាទក្រហមកម្ពុជា ក្នុងឱកាសបុណ្យខួបកំណើតគម្រប់ ៦៤ឆ្នាំ ឈានចូល ៦៥ឆ្នាំ

***សម្តេចកិត្តិព្រឹទ្ធបណ្ឌិតជាទីគោរពដ៏ខ្ពង់ខ្ពស់ !***

ក្នុងឱកាសបុណ្យខួបកំណើតគម្រប់ ៦៤ឆ្នាំ ឈានចូល ៦៥ឆ្នាំ របស់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ប្រធានកាកបាទក្រហមកម្ពុជា** ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៨ នេះ យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ មន្ត្រីរាជការគ្រប់ជាន់ថ្នាក់នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមគោរពជូនពរបវរមហាប្រសើរ ជូនចំពោះ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** សូមមានសុខភាពល្អបរិបូរណ៍ ថាមពលខ្លាំងក្លា ប្រាជ្ញាឈ្លាសវៃ និងមានសុភមង្គលដ៏ត្រចះត្រចង់។

ក្នុងឱកាសដ៏មហាកិត្តិយសនេះ យើងខ្ញុំទាំងអស់គ្នា សូមគោរពកោតសរសើរដ៏ស្មោះចំពោះ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ដែលជាកុលធីតាខ្មែរដ៏ឆ្នើមមួយរូប ជាឧត្តមភរិយា **សម្តេចតេជោនាយករដ្ឋមន្ត្រី** ដ៏ប្រពៃ ជាមាតាដ៏ល្អ ជាជីដូនដែលមានព្រហ្មវិហារធម៌ មានស្នាដៃដ៏ប៉ិនប្រសប់ និងគំនិតប្រាជ្ញាដ៏ឧត្តុង្គឧត្តមឈ្លាសវៃ ក្នុងការដឹកនាំកាកបាទក្រហមកម្ពុជា ដើម្បីបំពេញបេសកកម្មមនុស្សធម៌ដ៏ថ្លៃថ្លាប្រកបដោយគុណធម៌ សប្បុរសធម៌ និងបានចលនាភរិយាថ្នាក់ដឹកនាំជាច្រើនរូបទៀត រួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការយកចិត្តទុកដាក់ដោះស្រាយទុក្ខលំបាកជូនប្រជាពលរដ្ឋរងគ្រោះគ្រប់រូប គ្រប់ទីកន្លែងនៅទូទាំងប្រទេស និងបានខិតខំលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងតម្លៃគ្រួសារខ្មែរឱ្យបានខ្ពង់ខ្ពស់រុងរឿង។

សូម **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ដែលជាភរិយាដ៏ឧត្តុង្គឧត្តមនៃ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ព្រមទាំងបុត្រា-បុត្រី ចៅប្រុស-ចៅស្រីទាំងអស់ ទទួលបាននូវពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខគ្រប់ប្រការ និងសូមប្រកបតែសុខភាពល្អបរិបូរណ៍ អាយុយឺនយូរ កម្លាំងខ្លាំងក្លា ប្រាជ្ញាឈ្លាសវៃ ដើម្បីដឹកនាំកាកបាទក្រហមកម្ពុជា ទទួលបានជោគជ័យត្រចះត្រចង់ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា មេត្តាទទួលនូវគារវកិច្ចដ៏ស្មោះស្ម័គ្រ និងអភិវន្ទនកិច្ចដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំទាំងអស់គ្នា។

*ថ្ងៃ អង្គារ ៤ កើត ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២*

*រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែធ្នូ ឆ្នាំ២០១៨*

**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

រដ្ឋមន្ត្រី

**អ៊ិត សំហេង**

*អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩*